ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

# សុន្ទរកថាគន្លឹះ
# លោកជំទាវបណ្ឌិត ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស
# ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងសិក្ខាសាលាតម្រង់ទិសអំពី "កម្មវិធីលទ្ធភាពទទួលបានហិរញ្ញវត្ថុ"

ថ្ងៃសុក្រ ១៥រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ត្រូវនឹងថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ០៨:៣០-១២:០០ ថ្ងៃត្រង់
នៅសណ្ឋាគារ អូឡាំព្យារស៊ីធី និងតាមប្រព័ន្ធអនឡាញ

ជាបឋម ខ្ញុំសូមគោរព៖

- លោកឧកញ៉ា ប៉ិច ប៉ូឡែន អនុប្រធានប្រតិបត្តិ សមាគមសហគ្រិនវ័យក្មេងកម្ពុជា និងជាអគ្គនាយកក្រុមហ៊ុនវេសឡាញ អេឌ្យូខេសិនគ្រុប (Westline Education Group Co., Ltd.)
- លោក Raymond Sia Say Guan ប្រធានក្រុមប្រឹក្សាភិបាលសមាគមធនាគារនៅកម្ពុជា និងជាប្រធាននាយកប្រតិបត្តិ ធនាគារកាណាឌីយ៉ា
- លោក សុខ រឿន ប្រធានក្រុមប្រឹក្សាភិបាលសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងជាប្រធាននាយកប្រតិបត្តិ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី
- លោកស្រី សាប៊ីន យ៉ៅគ្គីស (Sabine Joukes) ប្រធានអង្គការជេកកម្ពុជា និងជាប្រធានគ្រប់គ្រងគម្រោង Women Entrepreneurs Act (WE Act)
- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងភ្ញៀវកិត្តិយសដែលមានវត្តមានក្នុងសិក្ខាសាលានេះផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ជាទីមេត្រី!

ថ្ងៃនេះ នាងខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយដែលបានចូលរួមក្នុងសិក្ខាសាលាតម្រង់ទិសស្តីពី **"កម្មវិធីលទ្ធភាពទទួលបានហិរញ្ញវត្ថុ"** ដែលមានគោលបំណងបង្កើនការយល់ដឹងដល់សហគ្រាសធុនតូចនិងមធ្យមឱ្យកាន់តែច្បាស់អំពីដំណើរការក្នុងការរៀបចំខ្លួន ដើម្បីទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ សមាគមសហគ្រិនវ័យក្មេងកម្ពុជា សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

ដែលបានយកចិត្តទុកដាក់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ។

ទោះជាយ៉ាងនេះក៏ដោយ ការសិក្សាបានបង្ហាញថា សហគ្រាសធុនតូចនិងមធ្យមប្រឈមនឹងឧបសគ្គមួយចំនួនដែលតម្រូវឱ្យយើងត្រូវយកចិត្តទុកដាក់ដើម្បីស្វែងរកដំណោះស្រាយ និងជំរុញវិស័យនេះឱ្យកាន់តែរីកចម្រើននិងអាចមានសមត្ថភាពទាញយកកាលានុវត្តភាពបាន។ ក្នុងនោះ ការទទួលបានសេវាហិរញ្ញវត្ថុគឺជាឧបសគ្គមួយរបស់ សហគ្រាសធុនតូចនិងមធ្យម ដោយសារការខ្វះទ្រព្យធានា ការបំពេញលក្ខខណ្ឌនៃការទទួលឥណទាន ការខ្វះនូវរបាយការណ៍ហិរញ្ញវត្ថុ និងការខ្វះនូវចំណេះដឹងផ្នែកហិរញ្ញវត្ថុ ជាដើម។ ម្យ៉ាងវិញទៀត ចាប់ពីដើមឆ្នាំ២០២០មក វិបត្តិកូវីដ១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងមកលើសេដ្ឋកិច្ច ហើយក៏ប៉ះពាល់មកដល់ដំណើរការអាជីវកម្មរបស់សហគ្រាសធុនតូចនិងមធ្យមផងដែរ ដូចជា ការធ្លាក់ចុះនូវប្រាក់ចំណូល ការកកស្ទះនូវសង្វាក់ផលិតកម្ម និងលទ្ធភាពនៃការបំពេញកាតព្វកិច្ចតាមកិច្ចសន្យាឥណទានជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ខណៈដែលសហគ្រាសទាំងនេះត្រូវការធនធានហិរញ្ញវត្ថុបន្ត និងពង្រឹងដំណើរការអាជីវកម្ម។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងភ្ញៀវកិត្តិយសជាទីមេត្រី!**

បរិយាបន្នហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ថាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ការបង្រួមគម្លាតសង្គម ការបង្កើននវានុវត្តន៍នៅក្នុងសង្គម ដែលជាកាតាលីករយ៉ាងសំខាន់នៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ជាក់ស្តែង ការបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុដល់ប្រជាជនជាពិសេសសហគ្រាសធុនតូចនិងមធ្យម នឹងផ្តល់ប្រយោជន៍ជាច្រើនទាំងផ្នែកសង្គម និងសេដ្ឋកិច្ច ដូចជា ការជួយសម្រួលដល់ជីវភាពរស់នៅ ការផ្តល់លទ្ធភាពឱ្យមានការសន្សំហិរញ្ញវត្ថុ និងការបង្កើនឱកាសធុរកិច្ច ដែលនាំឱ្យប្រជាជនកាន់តែមានលទ្ធភាពច្រើនជាងមុនក្នុងការទទួលបានសេវាចាំបាច់នានា (រួមមាន ការលើកកម្ពស់ការអប់រំ សេវាសុខភាព អនាម័យ និងទឹកស្អាត) ហើយសហគ្រាសធុនតូចនិងមធ្យម ក៏ទទួលបានផលប្រយោជន៍ផងដែរ ដូចជា ការបង្កើនលទ្ធភាពវិនិយោគ ការទទួលបានសេវាប្រឹក្សា និងការពង្រីកទីផ្សារ ជាដើម។

ក្នុងបរិការណ៍នេះ យុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ត្រូវបានរៀបចំឡើងក្នុងក្របខ័ណ្ឌជាគោលនយោបាយជាតិ និងជាផ្នែកមួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ ដែលមានផែនការសកម្មភាពគ្រប់ជ្រុងជ្រោយនិងច្បាស់លាស់ និងទ្រទ្រង់ដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវប្រព័ន្ធហិរញ្ញវត្ថុមួយមានស្ថិរភាព ប្រសិទ្ធភាព និងពិពិធកម្មទីផ្សារហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន។ យុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល ដោយមានគោលដៅ **បង្កើនលទ្ធភាពទទួលបានសេវា**

ហិរញ្ញវត្ថុផ្លូវការដែលមានគុណភាព កាត់បន្ថយអត្រាស្ត្រីដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុឱ្យបាន ពាក់កណ្តាលពី ២៧% មក ១៣% និងពង្រីកការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការពី ៥៩% ទៅ ៧០% ត្រឹមឆ្នាំ២០២៥ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពគ្រួសារ និងគាំទ្រកំណើនសេដ្ឋកិច្ច តាមរយៈសកម្មភាពអាទិភាពចំនួន ៦ រួមមាន៖

១- លើកទឹកចិត្តឱ្យមានការសន្សំនៅតាមគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ

២- ជំរុញនវានុវត្តន៍សេវាឥណទាន សម្រាប់សហគ្រាសធុនតូចនិងមធ្យម

៣- ពង្រីកសមត្ថភាពប្រព័ន្ធទូទាត់

៤- ពង្រីកការផ្តល់សេវាធានារ៉ាប់រងឱ្យបានទូលំទូលាយ

៥- ពង្រឹងសមត្ថភាពនិយ័តករវិស័យហិរញ្ញវត្ថុ និង

៦- លើកកម្ពស់សិទ្ធិនិងបង្កើនកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុ។

ក្នុងន័យនេះ វិស័យសហគ្រាសធុនតូចនិងមធ្យមត្រូវបានទទួលការយកចិត្តទុកដាក់និងជ្រោមជ្រែងពីរាជរដ្ឋាភិបាល ក៏ដូចជាធនាគារជាតិនៃកម្ពុជា។ ជាក់ស្តែង នៅឆ្នាំ២០២០ ធនាគារសហគ្រាសធុនតូចនិងមធ្យមបានលេចរូបរាងឡើង ដើម្បីជួយសម្រួលនីតិវិធីក្នុងការទទួលហិរញ្ញប្បទាន កាត់បន្ថយថ្លៃដើម ជំរុញដល់ផលិតភាពនិងប្រសិទ្ធភាព និងផ្តល់ការប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុដល់សហគ្រាសធុនតូច-និងមធ្យម។ ក្នុងឆ្នាំ២០២០នេះដដែល សាជីវកម្មធានាឥណទានកម្ពុជាត្រូវបានបង្កើតឡើងដើម្បីជំរុញការទទួលបានឥណទានដល់សហគ្រាសធុនតូចនិងមធ្យមដែលខ្វះទ្រព្យធានា តាមរយៈការធានាលើឥណទានដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ហើយកាលពីសប្តាហ៍មុន សាជីវកម្មធានាឥណទានកម្ពុជា ក៏បានដាក់ចេញនូវគម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី (CGCC Women Enterprise Guarantee Scheme) ដើម្បីគាំទ្រដល់សហគ្រិនស្ត្រី ជាពិសេស សហគ្រិនស្ត្រីដែលខ្វះទ្រព្យធានានៅពេលស្នើសុំកម្ចី ឱ្យមានលទ្ធភាពទទួលបានហិរញ្ញប្បទានផ្លូវការច្រើនជាងមុន និងងាយស្រួលជាងមុនសម្រាប់ទុនបង្វិល និងពង្រីកអាជីវកម្ម។ ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជាបានចុះអនុស្សារណៈយោគយល់ជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) លើការអនុវត្តគម្រោងស្តីពី ការអភិវឌ្ឍទីផ្សារខ្សែចង្វាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុនៅកម្ពុជា (Cambodia Supply Chain Finance Market Development) ក្នុងគោលបំណងអភិវឌ្ឍទីផ្សារខ្សែចង្វាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុ ដើម្បីពង្រឹងលទ្ធភាពដល់ការទទួលបានហិរញ្ញប្បទានសម្រាប់អាជីវកម្មនៅកម្ពុជា ជាពិសេស សហគ្រាសធុនតូចនិងមធ្យម ព្រមទាំងពង្រឹងខ្សែចង្វាក់ផលិតកម្មនៅកម្ពុជា។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងភ្ញៀវកិត្តិយសជាទីមេត្រី!**

ផលប៉ះពាល់ជាអវិជ្ជមានពីការរាលដាលជាសកលនៃជំងឺកូវីដ-១៩ បានបន្តអូសបន្លាយមកដល់បច្ចុប្បន្ន។ ក្នុងការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវវិធានការចាំបាច់ជាបន្តបន្ទាប់ ដើម្បីទប់ស្កាត់និងកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នានាមកលើប្រព័ន្ធធនាគារទាំងមូល។ តាមរយៈកិច្ចខិតខំប្រឹងប្រែងនេះ ប្រព័ន្ធធនាគារនៅកម្ពុជាអាចបន្តរក្សាបាននូវភាពរឹងមាំ ភាពធន់ និងជំនឿទុកចិត្តរបស់សាធារណជន ដែលសរបញ្ជាក់ដោយទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការកើនឡើងនៃការដាក់ប្រាក់បញ្ញើ ការប្រើប្រាស់សេវាទូទាត់ដោយកាបូបអេឡិចត្រូនិក (e-Wallet) ជាដើម។ ជាក់ស្តែង គិតត្រឹមដំណាច់ឆ្នាំ២០២១ ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារមានកំណើន ១៧,២% ឥណទានអតិថិជនមានកំណើន ២២,៧% និងប្រាក់បញ្ញើអតិថិជនមានកំណើន ១៦,៥% ដែលបង្ហាញអំពីជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ។ ទន្ទឹមនេះ ចំនួនគណនីប្រាក់បញ្ញើអតិថិជននិងគណនីឥណទានអតិថិជនបានកើនឡើងដល់ ១២,៧ លានគណនី និង ៣,៤ លានគណនីរៀងគ្នា ដែលបានឆ្លុះបញ្ចាំងពីកំណើននៃការទទួលបានសេវាហិរញ្ញវត្ថុរបស់ប្រជាជនកម្ពុជា។

ជាមួយគ្នាផងដែរ សេវាទូទាត់សងប្រាក់មានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងបានវិវឌ្ឍន៍ទៅរកការទូទាត់បែបឌីជីថល ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន ជាពិសេសសហគ្រាសធុនតូច និងមធ្យម លើសេវាទូទាត់ថ្មីៗប្រកបដោយនវានុវត្តន៍ ងាយស្រួល សុវត្ថិភាព និងចំណាយតិច។ តាមរយៈការទូទាត់បែបឌីជីថល អតិថិជនអាចធ្វើប្រតិបត្តិការដោយផ្ទាល់ដោយប្រើប្រាស់កម្មវិធីទូទាត់ចល័ត ឬនៅតាមបញ្ជរភ្នាក់ងារ និងបណ្តាញទូទាត់ជាច្រើននៅទូទាំងប្រទេស ដែលជួយលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ជំរុញការប្រកួតប្រជែង បង្កើនភាពច្នៃប្រឌិត និងផ្តល់នូវជំនឿទុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់សេវាទូទាត់សងប្រាក់។ ជាក់ស្តែង នៅក្នុងបរិបទនៃការរាលដាលជំងឺកូវីដ-១៩ ការប្រើប្រាស់សេវាទូទាត់សងប្រាក់មានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយអតិថិជនបានផ្លាស់ប្តូរឥរិយាបទពីការទូទាត់ជាសាច់ប្រាក់ មកជាការទូទាត់បែបឌីជីថល។ គិតត្រឹមដំណាច់ឆ្នាំ២០២១ អតិថិជនចុះឈ្មោះបង្កើតគណនីកាបូបអេឡិចត្រូនិក (e-Wallet) មានចំនួន ១៣,៦ លាននាក់ និងភ្នាក់ងារមានចំនួន ៩៦.២៧៨ ទីតាំង។

ជាមោទនភាពជាតិផងដែរ ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់ប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេនបានអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចធ្វើការទូទាត់ និងផ្ទេរប្រាក់ភ្លាមៗពីគ្រឹះស្ថានមួយទៅគ្រឹះស្ថានមួយ តាមរយៈកម្មវិធីធនាគារនៅលើទូរស័ព្ទដៃប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព។ ការផ្តល់ភាពងាយស្រួលក្នុងការទទួលបានសេវាទូទាត់នេះ បានបង្កើនចំនួនប្រជាជនប្រើប្រាស់សេវាទូទាត់ដល់ប្រមាណ ៨ លាននាក់ ស្មើនឹងប្រមាណ ៨០% នៃប្រជាជនពេញវ័យសរុប។ ជាមួយគ្នានេះ ប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) ក៏

ត្រូវបានបង្កើតឡើងផងដែរ ដើម្បីសម្រួលរាល់ការទូទាត់តាមកាតធនាគារនៅក្នុងប្រព័ន្ធទូទាត់ក្នុងស្រុក ទន្ទឹមគ្នានឹងការប្រើប្រាស់វីសា ឬម៉ាស្ទើកាត។

ស្របគ្នានឹងការជំរុញការទទួលបានសេវាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ក្នុងការបង្កើនចំណេះដឹងហិរញ្ញវត្ថុដល់ប្រជាជនទូទៅជាពិសេស សហគ្រាសធុនតូចនិងមធ្យម ដូចជា៖

- កិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដោយដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ ចាប់ពីកម្រិតបឋមសិក្សាដល់មធ្យមសិក្សាទុតិយភូមិ
- កិច្ចសហការជាមួយ ក្រសួងកិច្ចការនារី ដើម្បីអនុវត្តគម្រោង "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី" ដែលមានគោលដៅក្នុងការបណ្តុះបណ្តាលគ្រូបង្គោលដែលជាស្ត្រីនៅតាមសាលារៀន និងសហគមន៍ ដើម្បីអាចចែករំលែកចំណេះដឹងផ្នែកហិរញ្ញវត្ថុបន្តនៅក្នុងមូលដ្ឋានរបស់ខ្លួន
- កិច្ចសហការជាមួយ អង្គការ UNESCAP ដើម្បីអនុវត្តគម្រោង "ការជំរុញសហគ្រិនភាពរបស់ស្ត្រី (Catalyzing Women's Entrepreneurship)" ដើម្បីបង្កើតនូវវគ្គបណ្តុះបណ្តាលដល់ស្ត្រី និងសហគ្រិនជាស្ត្រី ក្នុងគោលដៅបង្កើនការយល់ដឹង លទ្ធភាពទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ
- កិច្ចសហការជាមួយអង្គការ Good Return ក្នុងការរៀបចំយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយ" និង "តោះ! និយាយពីលុយ៖ តក់ៗពេញបំពង់" និង
- ការផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ក្នុងគោលដៅបន្តពង្រឹងចំណេះដឹងពាក់ព័ន្ធនឹងវិស័យធនាគារនិងហិរញ្ញវត្ថុ ជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុ ការធានាឱ្យមានការរីកចម្រើនប្រកបដោយប្រសិទ្ធភាព ស្ថិរភាព តម្លាភាព និងការពារអត្ថប្រយោជន៍ជូនប្រជាជន។

បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជា តែងតែយកចិត្តទុកដាក់ពង្រឹងយន្តការគ្រប់គ្រងនិងគាំទ្រកិច្ចការពារអតិថិជនក្នុងការដោះស្រាយបណ្តឹងដោយការសម្របសម្រួលរវាងអតិថិជន និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈលេខទូរស័ព្ទ Hotline របស់ធនាគារជាតិនៃកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាពទាន់ពេលវេលា និងមានសង្គតិភាព។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងភ្ញៀវកិត្តិយសជាទីមេត្រី!**

ជារួម ការទទួលបានហិរញ្ញប្បទានរបស់សហគ្រាសធុនតូចនិងមធ្យម ប្រៀបបានជាការទទួលឱសថជំសាកសិទ្ធដើម្បីបំប៉នអាជីវកម្ម និងធ្វើឱ្យអាជីវកម្មកាន់រីកធំធាត់បន្ថែមទៀត។ បើទោះជាយ៉ាង

នេះក៏ដោយ ការប្រើប្រាស់ហិរញ្ញប្បទានដែលទទួលបាន ទាមទារឱ្យមាននូវចំណេះដឹងផ្នែកហិរញ្ញវត្ថុដ៏សមស្របដើម្បីប្រើប្រាស់ហិរញ្ញប្បទានទាំងនេះប្រកបដោយគុណភាព ប្រសិទ្ធភាព និងភាពវៃឆ្លាតស្របតាមទំហំនៃតម្រូវការ។ ក្នុងឱកាសនេះផងដែរ ខ្ញុំក៏សូមលើកទឹកចិត្តគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យយកចិត្តទុកដាក់ផ្តល់ឥណទានដល់សហគ្រាសធុនតូចនិងមធ្យម ដោយពិចារណាលើលទ្ធភាពនៃការសង ជាជាងទ្រព្យធានា ដូចជា ការប្រើប្រាស់ទិន្នន័យរបស់ការិយាល័យឥណទានកម្ពុជា ក្នុងការវិភាគនិងវាយតម្លៃគុណភាពអតិថិជន ដែលអាចជំរុញឱ្យអតិថិជនដែលពុំមានទ្រព្យបញ្ចាំអាចមានលទ្ធភាពទទួលបានហិរញ្ញប្បទាន ដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាជននិងគាំទ្រកំណើនសេដ្ឋកិច្ចក៏ដូចជាការបង្កើនឱកាសដល់គ្រឹះស្ថានក្នុងការពង្រីកចំណែកទីផ្សារឥណទានដែលមានភាពរឹងមាំ។

ខ្ញុំជឿជាក់ថា សិក្ខាសាលាតម្រង់ទិសស្តីពី "**កម្មវិធីលទ្ធភាពទទួលបានហិរញ្ញវត្ថុ**" នេះ នឹងផ្តល់ឱកាសដល់សហគ្រិនដែលជាម្ចាស់សហគ្រាសធុនតូច និងមធ្យម ជាពិសេសសហគ្រិនស្ត្រី ឱ្យយល់ដឹងកាន់តែច្បាស់អំពីដំណើរការ និងលក្ខណ្ឌដើម្បីទទួលបានហិរញ្ញប្បទានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ជាចុងក្រោយ ខ្ញុំក៏សូមកោតសរសើរសារជាថ្មី ចំពោះសមាគមសហគ្រិនវ័យក្មេងកម្ពុជា សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលបានផ្តួចផ្តើមឱ្យមានវេទិកានេះឡើង និងសូមថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងភ្ញៀវកិត្តយស ដែលបានយកចិត្តទុកដាក់ស្តាប់ការធ្វើបទអន្តរាគមន៍របស់ខ្ញុំ។ ខ្ញុំក៏សូមជូនពរ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងភ្ញៀវកិត្តយស ដែលមានវត្តមានទាំងនៅទីនេះផ្ទាល់ និងតាមប្រព័ន្ធអនឡាញ សូមមានសុខភាពល្អ កម្លាំងមាំមួន ជោគជ័យគ្រប់ភារកិច្ច និងជៀសឆ្ងាយពីជំងឺកូវីដ-១៩។

***សូមអរគុណ!***